# គន្លឹះទាំង៧ សម្រាប់ជួយដល់កុមារ

ChildSafe MOVEMENT
TOGETHER, PROTECTING CHILDREN

រួមគ្នាការពារកុមារ

រៀបចំដោយ friends international

## ១ សូមជួយគាំទ្រ ភ្នាក់ងារសុវត្ថិភាពកុមារ

ភ្នាក់ងារសុវត្ថិភាពកុមាររួមមាន អ្នករត់ម៉ូតូឌុប ម៉ូតូរ៉ឺម៉ក បុគ្គលិកផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន ក្រុមហ៊ុនទេសចរណ៍ និងអ្នកលក់ដូរ ។ល។ ភ្នាក់ងារទាំងអស់បានទទួលការបណ្តុះបណ្តាល និងអាចការពារ និងធ្វើអន្តរាគមន៍ភ្លាមៗ នៅពេលដែលកុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។

ChildSafe Certified.

( ស្លាកសញ្ញាភ្នាក់ងារសុវត្ថិភាពកុមារ )

ប្រើប្រាស់សេវាកម្មរបស់ភ្នាក់ងារសុវត្ថិភាពកុមារ មានន័យថា អ្នកបានចូលរួមចំណែកការពារកុមារ។

សូមស្វែងរកភ្នាក់ងារសុវត្ថិភាពកុមារ ដែលមានស្លាកសញ្ញាសុវត្ថិភាពកុមារ ChildSafe Certified. ។

## ២ សូមពិចារណា! មុននឹងទិញសម្ភារៈ ឬឲ្យលុយទៅកុមារសុំទាន

ការទិញ ឬ ការដាក់ទានដល់កុមារ មិនមែនជាជម្រើសល្អក្នុងការធ្វើទាននោះទេ មានន័យថាអ្នកកំពុងគាំទ្រ ឬទុកពួកគេអោយស្ថិតក្នុងស្ថានភាពងាយរងគ្រោះនៅតាមដងផ្លូវ មិនបានទៅសាលារៀន និងងាយរងគ្រោះដោយការរំលោភបំពានផ្សេងៗ ការកេងប្រវ័ញ្ច ។ល។

មានអង្គការជាច្រើនកំពុងធ្វើការដើម្បីជួយកុមារសុំទានអោយចេញផុតពីជីវិតតាមថ្នល់។

សូមគាំទ្រអង្គការណាដែលការពារកុមារ និងធានាបានថាកុមារ និងគ្រួសាររបស់ពួកគេមានអនាគតប្រសើរជាងមុន។

## ៣ សូមធានាថា កូនៗរបស់អ្នក មានសុវត្ថិភាពនៅពេលអ្នកបើកបរ

រាងកាយរបស់កុមារមានភាពទន់ខ្សោយណាស់។ ដូច្នេះគ្រោះថ្នាក់ចរាចរណ៍ អាចធ្វើឲ្យកុមារងាយស្លាប់ និងរងរបួសធ្ងន់ ប្រសិនបើអ្នកមិនបានពាក់មួក ឬ ខ្សែក្រវាត់សុវត្ថិភាពឲ្យកុមារពេលអ្នកបើកបរ។

ការពារកូនៗរបស់អ្នក នៅពេលអ្នកបើកបរម៉ូតូ ត្រូវពាក់មួកសុវត្ថិភាពឲ្យកូនអ្នក និងនៅពេលបើកបររថយន្ត ត្រូវដាក់កូនអ្នកនៅកៅអីខាងក្រោយ ហើយពាក់ខ្សែក្រវាត់សុវត្ថិភាព។

## ៤



## សូមរក្សាកុមារឲ្យរស់នៅជុំគ្នាក្នុងគ្រួសារ ប្រសើរជាងឲ្យកុមារទៅរស់នៅក្នុង មណ្ឌលកុមារកំព្រា

មណ្ឌលកុមារកំព្រាមិនមែនសុទ្ធតែជាជម្រើសល្អសម្រាប់កុមារឡើយ។ មណ្ឌលកុមារកំព្រាជាច្រើនអះអាងថា នឹងផ្តល់អាហារ ការអប់រំ និងការថែទាំដ៏ល្អ ប៉ុន្តែជារឿយៗ មណ្ឌលទាំងនោះមិនគោរពតាមការសន្យាទាំងនោះទេ។ ការបញ្ជូនកុមារទៅរស់នៅក្នុងមណ្ឌលកុមារកំព្រាមានន័យថាពួកគេឃ្លាតឆ្ងាយពីគ្រួសារ ខ្វះភាពរីករាយ បាត់បង់ភាពកក់ក្តៅ ពិបាកទទួលសេចក្តីស្រឡាញ់ និងបង្អាក់ការអភិវឌ្ឍន៍របស់កុមារ។ កុមារមានអនាគតល្អប្រសើរត្រូវតែទទួលការថែទាំក្នុងបរិយាកាសគ្រួសាររបស់ពួកគេ។

**មានអង្គការជាច្រើនកំពុងធ្វើការដើម្បីរក្សាកុមារឲ្យរស់នៅក្នុងគ្រួសារ។**

**ប្រសិនបើអ្នកដឹងថាមានគ្រួសារណាដែលត្រូវការជំនួយ សូមទាក់ទងមកលេខទូរស័ព្ទសុវត្ថិភាពកុមារដែលមាននៅក្នុងគន្លឹះលេខ៧**

## ៥



## សូមពិចារណា! មុននឹងឲ្យកូនរបស់អ្នកធ្វើចំណាកស្រុក ទៅធ្វើការនៅទីក្រុង ឬក្រៅប្រទេស

កុមារ និងយុវវ័យធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ឬទៅសុំទាន។

ជាញឹកញាប់ពួកគេតែងតែត្រូវបានគេកេងប្រវ័ញ្ច រំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និង ផ្លូវភេទ។ ភាគច្រើនពួកគេត្រូវបានបង្ខំឲ្យធ្វើការងារដោយមិនបានលុយ ឬប្រាក់ខែ ទោះបីជាបានចុះកិច្ចសន្យាការងារក៏ដោយ។

សូមប្រាកដថារាល់ការធ្វើចំណាកស្រុករបស់កុមារ ឬគ្រួសារ ត្រូវតែមានព័ត៌មាន ច្បាស់លាស់ និងត្រៀមខ្លួនជាមុន។

**សូមការពារខ្លួនអ្នក និងមិត្តភ័ក្តិរបស់អ្នក។ សូមទាក់ទងមកលេខទូរស័ព្ទសុវត្ថិភាពកុមារដែលមាននៅក្នុងគន្លឹះលេខ៧ ដើម្បីទទួលបានព័ត៌មានស្តីអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ឬរាយការណ៍ ប្រសិនបើអ្នកសង្ស័យថាជនណាម្នាក់ត្រូវបានគេកេងប្រវ័ញ្ច ឬ បង្ខំឲ្យធ្វើការងារ។**

## ៦



## សូមពិចារណា! ពីវិធីការពារកុមារឲ្យរួចផុតពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ

កុមារប្រឈមមុខខ្ពស់នឹងការបំពានផ្លូវភេទ ការបោកប្រាស់យកទៅលក់ ដោយជនដែលស្គាល់ និងជឿទុកចិត្តទៅឲ្យធ្វើពេស្យាចារដែលធ្វើឲ្យរងការប៉ះទង្គិច ផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ។

ការពារកុមារនៅក្នុងសហគមន៍របស់អ្នក និងរាយការណ៍នៅពេលដែលសង្ស័យថាមានករណីរំលោភបំពានកុមារ។

ការរួមភេទជាមួយកុមារជាអំពើខុសច្បាប់។ នៅពេលដែលអ្នកទៅកន្លែងកម្សាន្តដូចជា ភោជនីយដ្ឋាន ក្លឹប ខារ៉ាអូខេ ជៀសវាង រួមភេទជាមួយកុមារព្រោះអ្នកអាចប្រឈមមុខនឹងការជាប់ពន្ធនាគារ។

**ប្រសិនបើអ្នកឃើញឬសង្ស័យករណីរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ សូមទាក់ទងមកលេខទូរស័ព្ទសុវត្ថិភាពកុមារ ឬប៉ូលិសដែលមាននៅក្នុងគន្លឹះលេខ៧ ដើម្បីធ្វើការជួយអន្តរាគមន៍បន្ទាន់។**

## ៧



## សូមពិចារណា! ពីវិធីការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងការមិនយកចិត្តទុកដាក់

កុមារជាច្រើនក្នុងប្រទេសកម្ពុជានៅតែរងការវាយដំលើរាងកាយ ការគម្រាមកំហែង ហើយមិនត្រូវបានគេយកចិត្តទុកដាក់ និងថែទាំដឹតដល់នៅពេលមានជំងឺ ឬស្ថិតក្នុងស្ថានភាពរំលោភបំពានផ្សេងៗ។

**ប្រសិនបើអ្នកឃើញ ឬ សង្ស័យករណីរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត ឬការមិនយកចិត្តទុកដាក់ សូមទាក់ទងមកលេខទូរស័ព្ទសុវត្ថិភាពកុមារ(២៤ម៉ោង)៖**

**012 311 112 (ភ្នំពេញ)**
**017 358 758 (សៀមរាប)**
**012 478 100 (ព្រះសីហនុ)**
**012 557 188 (កំពង់ចាម)**
**095 960 303 (ប៉ោយប៉ែត)**
**089 500 008 (អ្នកលឿង)**
**092 911 115 (បាត់ដំបង)**

**ប៉ូលិសអន្តរាគមន៍បន្ទាន់ (023 997 919 ឬ 1288)**